# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកក្កដា ឆ្នាំ២០២២

នៅក្នុងខែកក្កដា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

#### ១.១.១-បដិសណ្ឋារកិច្ចឡើវជាតិ និងអន្តរជាតិ

-អនុញ្ញាតឱ្យឯកឧត្តម **ដុ វ៉ាន់ចៀន** (Đỗ Văn Chiến) គណៈលេខាមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានគណៈកម្មាធិការមជ្ឈឹមរណសិរ្សមាតុភូមិវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ។

-អនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍ចំនួន២៨រូប ដែលត្រូវចេញទៅសិក្សានៅប្រទេសជប៉ុនក្នុងឆ្នាំ២០២២-២០២៣ ចូលជួបសម្តែងការគួរសម។

#### ១.១.២-សកម្មភាពចុះមូលដ្ឋាន

-បានចុះពិនិត្យការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ មានការស្តាបនាផ្លូវជាតិលេខ១០ពីសំឡូត-វាលវែង-កោះកុង និងបានចុះសួរសុខទុក្ខកងកម្លាំងមានសមត្ថកិច្ចចម្រុះប្រចាំការនៅច្រកទ្វារតំបន់៨០០សំឡូត ស្ថិតក្នុងឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង និងបានឧបត្ថម្ភថវិកាជូនកងកម្លាំងចំនួន២០លានរៀល ដើម្បីឈូសឆាយរៀបចំដីសម្រាប់សាងសង់ កន្លែងស្នាក់នៅរបស់កងកម្លាំងមានសមត្ថកិច្ចនៅទីនោះ។

#### ១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានឧបត្ថម្ភថវិកាចំនួន១០,០០០$ (មួយម៉ឺនដុល្លារ)ជូនដល់រាជរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាមីននៅកម្ពុជា។

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធី "រុក្ខទិវា៩កក្កដា" ក្រោមព្រះរាជាធិបតី



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ភូមិសំបូរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង។

-បានអញ្ជើញនាំយកទេយ្យវត្ថុ និងទៀនព្រះវស្សាប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តអូរសោម ស្ថិតនៅក្នុងភូមិអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងវត្តវិសុទ្ធវង្សា ស្ថិតក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **លោក អាបេ ស៊ីនហ្សូ** អតីតនាយករដ្ឋមន្ត្រីជប៉ុន នៅស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធ និងផ្តល់ភ្លើងបូជាសពឯកឧត្តម **អ៊ឹង គៀត** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅវត្តបទុមវតី សង្កាត់ចតុមុខ រាជធានីភ្នំពេញ។

**១.១.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខា និងផ្តល់យោបល់លើឯកសារផ្សេងៗចំនួន១៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១ច្បាប់។

### ១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុម កា** អនុប្រធានទី១ ព្រឹទ្ធសភា

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន១លើក។

**១.២.១-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៩ច្បាប់។

### ១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា

**១.៣.១-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចុះពិនិត្យការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ មានការស្ថាបនាផ្លូវជាតិលេខ១០ពីសំឡូត-វាលវែង-កោះកុង និងបានចុះសួរសុខទុក្ខកងកម្លាំងមានសមត្ថកិច្ចចម្រុះប្រចាំការនៅច្រកទ្វារតំបន់៨០០សំឡូត ស្ថិតក្នុងឃុំស៊ុង

ស្រុកសំឡូត ខេត្តបាត់ដំបង។

**១.៣.២-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមក្នុងពិធីរុក្ខទិវា ៩កក្កដា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិសំបួរមាស ឃុំស្នឹង ស្រុកបាណន់ ខេត្តបាត់ដំបង។

-បានអញ្ជើញអមដំណើរសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញនាំយកទេយ្យវត្ថុ និងទៀនព្រះវស្សាប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តអូរសោម ស្ថិតក្នុងភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។

-បានអញ្ជើញអមដំណើរសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធលោក **អាបេ ស៊ីនហ្សូ** អតីតនាយករដ្ឋមន្ត្រីជប៉ុន នៅស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

-បានអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលី ដើម្បីលើកព្រះពុទ្ធបដិមាឡើងគង់លើពុទ្ធបាល័ង្កនៅក្នុងព្រះវិហារស្ថិតនៅក្នុងវត្តលុម្ពិនី ហៅវត្តអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។

-បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(Mou) រវាងគណៈកម្មការទី១០ ព្រឹទ្ធសភា ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដើម្បីផ្ដល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

**១.៣.៣-ការពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ចំនួន៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា តាមប្រព័ន្ធវីដេអូ។

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ។

## ២.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីស្វែងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យ ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តព្រះសីហនុ។

-បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃមន្ទីរកិច្ចការនារី មន្ទីរផែនការ រាជធានីភ្នំពេញ ដើម្បីស្វែងយល់ពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈមនានា។

-បានអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តព្រៃវែង ដើម្បីស្វែងយល់អំពីការពង្រឹងកិច្ចការរដ្ឋបាលឃុំ សង្កាត់ ក្រោយការបោះឆ្នោត សំដៅអភិវឌ្ឍន៍មូលដ្ឋានធានាបានសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

## ២.៣ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន៨ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៨ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធបានចំនួន២ករណី កំពុងពិនិត្យសិក្សាចំនួន៩ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន៨ករណីឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៨ករណី តម្កល់ទុកមិនចាត់ការចំនួន២ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន៥ករណី។

-បានអនុញ្ញាតឱ្យគណៈប្រតិភូសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកោះកុង ដឹកនាំដោយលោកជំទាវ **មិថុនា ភួថង** អភិបាលនៃគណៈអភិបាលខេត្ត និងជាអនុប្រធានកិត្តិយសសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកោះកុង អញ្ជើញជួបសំណេះសំណាល និងសម្តែងការគួរសម ព្រមទាំងធ្វើសេចក្តីរាយការណ៍អំពីវឌ្ឍនភាពការងារ និងបញ្ហានានារបស់ខេត្ត នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។

-បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំសំឡូត ឃុំ

មានជ័យ និងឃុំស៊ុង អំពីការពង្រឹងការងារដឹកនាំភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការអភិវឌ្ឍ ដើម្បីលើកស្ទួយកម្រិតជីវភាពរបស់ប្រជាកសិករ និងបន្តពង្រឹងវិធានសុខាភិបាល ស្ថិតនៅស្រុកសំឡូត ខេត្តបាត់ដំបង។

-បានអញ្ជើញចូលរួមប្រជុំជាមួយគណៈកម្មការកិច្ចការស្ត្រី និងកុមារ ដើម្បីស្តាប់របាយការណ៍ ស្តីពីវឌ្ឍនភាពការងាររបស់គណៈកម្មការកិច្ចការស្ត្រី និងកុមារ នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បានអញ្ជើញជាអធិបតីក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការពិនិត្យលើវឌ្ឍន-ភាពរបស់កម្ពុជាក្នុងដំណើរឆ្ពោះទៅកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិស្តីពីជំងឺរបេង (UNHLM-TB) ឆ្នាំ២០២៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

-បានអញ្ជើញចូលរួមជាវាគ្មិនស្តីពីកិច្ចពិភាក្សា និងចែករំលែកបទពិសោធន៍អំពីការចិញ្ចឹមជ្រូក និងទស្សនវិស័យឧស្សាហកម្មចិញ្ចឹមជ្រូកកម្ពុជា ជាមួយថ្នាក់ដឹកនាំកសិករសមាគមសណ្តែកសៀងអាមេរិក (ASA) ឆ្នាំ២០២២។

-បានអញ្ជើញជាអធិបតីក្នុងអង្គវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សាខណ្ឌទួលគោក អាណត្តិទី៣ ឆ្នាំ២០២២ អំពីសមិទ្ធផល ទទួលដោះស្រាយបញ្ហាប្រឈម និងសំណូមពរ ជូនបងប្អូនប្រជាពលរដ្ឋលើការអភិវឌ្ឍនៅមូលដ្ឋាន ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការបណ្តុះបណ្តាលធនធានមនុស្ស និងអភិបាលកិច្ចល្អ។

-បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការកសាងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា នៅវិមានរដ្ឋសភា។

-បានអញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិកាស្តីពី"យុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ " ដោយមានការចូលរួមពីថ្នាក់ដឹកនាំរដ្ឋបាលខេត្តកំពង់ឆ្នាំង ព្រមទាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រុមការងារមជ្ឈមណ្ឌលសភាអាស៊ី ស្ត្រីនៅមូលដ្ឋានធ្វើការអំពីសមភាពយេនឌ័រ អង្គភាពពាក់ព័ន្ធមួយចំនួនជុំវិញខេត្ត លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សប្រមាណជាង២២០នាក់ នៅខេត្តកំពង់ឆ្នាំង។

-បានអញ្ជើញចូលរួមកម្មវិធី Briefing ស្តីពីលទ្ធផលនៃដំណើរទស្សនកិច្ចការងារលើកទី២ របស់ប្រេសិតពិសេសនៃប្រធានអាស៊ាន ស្តីពីបញ្ហាមីយ៉ាន់ម៉ា នៅប្រទេសមីយ៉ាន់ម៉ា ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួង។

-បានអញ្ជើញជាកិត្តិយសក្នុងពិធីរុក្ខទិវា ៩កក្កដា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិសំបួរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង។

-បានអញ្ជើញនាំយកទៀនព្រះវស្សា ទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួនទៅវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅទីវត្តអារាម នៅរាជធានី ភ្នំពេញ និងតាមបណ្តាខេត្តនានា។

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន៥៨លើក។

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងសម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសអំពាវនាវដល់ប្រជាពលរដ្ឋឱ្យទៅចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសជំរុញឱ្យបានគ្រប់គ្នា នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ ខេត្តពោធិ៍សាត់ ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តស្ទឹងត្រែង និងខេត្តប៉ៃលិន ចំនួន១៩២លើក។

## ២.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម **ជា ជេដ្ឋ** ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា និងជាអនុប្រធានគណៈ-

កម្មាធិការអចិន្ត្រៃយ៍ក្រុមសភាជាតិកម្ពុជា (APF) ព្រមទាំងជាសមាជិកក្រុមការងារទទួលបន្ទុកការសើរើលក្ខន្តិកៈ(APF) បានអញ្ជើញចូលរួមមហាសន្និបាតលើកទី៤៧ នៃសភានិយាយភាសាបារាំង(APF) នៅទីក្រុងKagali ប្រទេសRwanda។

-ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក **Kim Jin Ho** តំណាងអង្គការ Global Life Sharing ប្រចាំនៅប្រទេសកម្ពុជា និងតំណាងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ចូលជួបពិភាក្សាការងារ។

**ថ្ងៃ** *ពុធ ៦ កើត* **ខែ***ស្រាពណ៍* **ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦**

**រាជធានីភ្នំពេញ, ថ្ងៃទី***០៣* **ខែសីហា ឆ្នាំ២០២២**

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>**ចម្លងជូន**</u>

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ខ្ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*